**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

ថ្ងៃព្រហស្បតិ៍ ៣កើត ខែជេស្ឋ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស. ២៥៦២
ភ្នំពេញ, ថ្ងៃទី១៧ ខែឧសភា ឆ្នាំ ២០១៨

លេខៈ ៣៩៣៦ ព.ម.កបទ.សអ

**ជម្រាបមក**
**ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត**
**លោក អគ្គកុងស៊ុល**

**<u>កម្មវត្ថុៈ</u>** ការផ្សព្វផ្សាយសេចក្តីអំពាវនាវរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

**<u>យោងៈ</u>** លិខិតរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ ៥២៩ គ.ជ.ប ចុះថ្ងៃទី ១៥ ខែឧសភា ឆ្នាំ២០១៨។

ខ្ញុំសូម ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត និងលោកអគ្គកុងស៊ុល ធ្វើការផ្សព្វផ្សាយសេចក្តីអំពាវនាវរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដូចមានជូនភ្ជាប់ជាមួយ ដល់ប្រជាពលរដ្ឋខ្មែរដែលកំពុងរស់នៅ និងធ្វើការនៅបរទេស បានជ្រាបពីកាលបរិច្ឆេទ នៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ លក្ខខណ្ឌដើម្បីអាចបោះឆ្នោតបាន និងអំពាវនាវឱ្យប្រជាពលរដ្ឋខ្មែរនៅក្រៅប្រទេសដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ឆ្នាំ២០១៧ វិលត្រឡប់មកកម្ពុជាវិញ ដើម្បីចូលរួមក្នុងការបោះឆ្នោតនាពេលខាងមុខនេះតាមកាលបរិច្ឆេទដែលបានកំណត់កុំបីខាន។

សូមឯកឧត្តម លោកជំទាវ និងអស់លោក ទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ។

**រដ្ឋមន្ត្រីស្តីទី**

**អ៊ុច បូររិទ្ធ**

អាសយដ្ឋានៈ លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីមែល : mfaic@mfa.gov.kh

Press

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

នាយកដ្ឋាន រដ្ឋបាលទូទៅ
ចូល លេខ 4768 រ.ទ.កបទ.សអ
ថ្ងៃទី 16 ខែ 05 ឆ្នាំ 18
ម៉ោង 15h00

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**
**លេខ:** ៥២៩ គ.ជ.ប

## សូមជម្រាបជូន
## ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

**កម្មវត្ថុ** : សំណើសុំកិច្ចសហការផ្សព្វផ្សាយសេចក្តីអំពាវនាវរបស់ គ.ជ.ប ដល់ប្រជាពលរដ្ឋខ្មែរ ដែលកំពុងបំពេញបេសកកម្ម ឬរស់នៅ និងធ្វើការនៅក្រៅប្រទេស តាមរយៈបណ្តាស្ថានទូត និងស្ថានកុងស៊ុលនៅក្រៅប្រទេស ។

**យោង** : - ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- តម្រូវការចាំបាច់របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមទេសរដ្ឋមន្ត្រី** ជ្រាបថា ក៏ដូចជាការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០១៧ កន្លងមកដែរ ក្នុងបំណងផ្សព្វផ្សាយអំពីកាលបរិច្ឆេទ និងលក្ខខណ្ឌសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ឆ្នាំ២០១៨ សំដៅឱ្យប្រជាពលរដ្ឋខ្មែរដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ឆ្នាំ២០១៧ ដែលកំពុងបំពេញបេសកកម្ម ឬរស់នៅ និងធ្វើការនៅក្រៅប្រទេស អាចមកចូលរួមបោះឆ្នោត តាមកាលបរិច្ឆេទដែលបានកំណត់ ។

ដូចនេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) សូមស្នើក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មេត្តាផ្តល់កិច្ចសហការផ្សព្វផ្សាយសេចក្តីអំពាវនាវរបស់ គ.ជ.ប ដល់ស្ថានទូត និងស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជានៅក្រៅប្រទេសទាំងអស់ ដើម្បីបន្តផ្សព្វផ្សាយដល់ប្រជាពលរដ្ឋដែលកំពុងស្នាក់នៅក្រៅប្រទេស បានជ្រាបអំពីកាលបរិច្ឆេទនៃការបោះឆ្នោត លក្ខខណ្ឌសម្រាប់បោះឆ្នោត និងអាចចូលរួមបោះឆ្នោតឱ្យបានគ្រប់ៗគ្នា ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមទេសរដ្ឋមន្ត្រី ពិនិត្យលទ្ធភាពផ្សព្វផ្សាយសេចក្តីអំពាវនាវនេះឱ្យបានទូលំទូលាយតាមរយៈបណ្តាស្ថានទូត និងស្ថានកុងស៊ុលទាំងអស់នៅក្រៅប្រទេសតាមការគួរ ។

សូម **ឯកឧត្តមទេសរដ្ឋមន្ត្រី** ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ ។
សូមជូនភ្ជាប់មកជាមួយសេចក្តីអំពាវនាវ ០១ច្បាប់ ។

ថ្ងៃអង្គារ ១កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ២០១៨

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**
**ប្រធាន**

**ស៊ិក ប៊ុនហុក**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
លេខ: ០០១ គ.ជ.ប

## សេចក្តីអំពាវនាវ
### ចំពោះប្រជាពលរដ្ឋខ្មែរ ដែលកំពុងបំពេញបេសកកម្ម ឬរស់នៅ និងធ្វើការនៅក្រៅប្រទេស

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត** (គ.ជ.ប) មានកិត្តិយសសូមជម្រាបជូនដល់ប្រជាពលរដ្ឋខ្មែរ ដែលកំពុងបំពេញបេសកកម្ម ឬរស់នៅ និងធ្វើការនៅក្រៅប្រទេសទាំងអស់ថា ៖

១. ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ នឹងប្រព្រឹត្តទៅនៅថ្ងៃអាទិត្យ ទី២៩ ខែកក្កដា ឆ្នាំ២០១៨ ចាប់ពីម៉ោង ៧:០០ព្រឹក រហូតដល់ម៉ោង ៣:០០រសៀល។

២. ដើម្បីបោះឆ្នោតបាន ប្រជាពលរដ្ឋខ្មែរត្រូវមានឈ្មោះក្នុងបញ្ជីបោះឆ្នោត និងត្រូវមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត ។ ករណីប្រជាពលរដ្ឋមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ហើយពុំមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរដើម្បីបោះឆ្នោត ប្រជាពលរដ្ឋអាចប្រើប្រាស់ឯកសារបញ្ជាក់អត្តសញ្ញាណដើម្បីបោះឆ្នោត ។ ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោតនឹងត្រូវធ្វើជូនប្រជាពលរដ្ឋ ចាប់ពីថ្ងៃទី២៨ ខែមិថុនា ដល់ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៨ ។

៣. ប្រជាពលរដ្ឋខ្មែរដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ឆ្នាំ២០១៧ និងកំពុងបំពេញបេសកកម្ម ឬរស់នៅ និងធ្វើការនៅក្រៅប្រទេស សូមវិលត្រឡប់មកប្រទេសកម្ពុជាវិញ ដើម្បីចូលរួមក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ឆ្នាំ២០១៨ នាពេលខាងមុខនេះ តាមកាលបរិច្ឆេទដែលបានកំណត់កុំបីខាន។

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត** សូមអំពាវនាវដល់បងប្អូនប្រជាពលរដ្ឋខ្មែរអញ្ជើញមកបោះឆ្នោតឱ្យបានគ្រប់ៗគ្នា ដើម្បីអនុវត្តសិទ្ធិរបស់ខ្លួន ហើយ គ.ជ.ប ស្នើសុំការសហការពីស្ថានទូតនៃព្រះរាជាណាចក្រកម្ពុជាទាំងអស់ មេត្តាជួយផ្សព្វផ្សាយសេចក្តីអំពាវនាវនេះដល់ប្រជាពលរដ្ឋខ្មែរ ដែលកំពុងបំពេញបេសកកម្ម ឬរស់នៅ និងធ្វើការនៅក្រៅប្រទេសឱ្យបានទូលំទូលាយ ។

ថ្ងៃចន្ទ ១៥រោច ខែពិសាខ ឆ្នាំច សំរឹទ្ធស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៨
ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
ប្រធាន

ស៊ិក ប៊ុនហុក